ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សិក្សាសង្ខេប
ស្តីពី
# ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា
(ចាប់ពីមុនឆ្នាំ១៩០៨ រហូតមកដល់បច្ចុប្បន្ន)

--កំណែទម្រង់វិជ្ជការនិងវិសហមជ្ឈការ

ឧទ្ទេសនាម
ដោយ
សម្តេចក្រឡាហោម ស ខេង
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ឆ្នាំសិក្សា ២០២២-២០២៣

## មាតិកា


I.ទិដ្ឋភាពទូទៅនៃមាតិកានិងមាតិការងដោយសង្ខេប ........ ១

១.គន្លឹះចងចាំមាតិកា ........ ១

២.គន្លឹះចងចាំមាតិការង ........ ១

៣.ពាក្យគន្លឹះគួរស្វែងយល់ ........ ២

II.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា........ ៣

១.ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ........ ៣

ក.មុនឆ្នាំ១៩០៨ ........ ៣

ខ.ចន្លោះឆ្នាំ១៩០៨ដល់១៩៥៥ ........ ៣

គ.ចន្លោះឆ្នាំ១៩៥៥ដល់១៩៧៥ ........ ៥

ឃ.ចន្លោះឆ្នាំ១៩៧៩ដល់១៩៩៣ ........ ៦

ង.ចាប់ឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន ........ ៦

ច.វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជា ........ ៦

២.ក្របខណ្ឌគោលនយោបាយសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ........ ១០

ក.យុទ្ធសាស្ត្រចតុកោណនិងយុទ្ធសាស្ត្របញ្ចកោណ ........ ១០

ខ.ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ........ ១០

៣.គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា........ ១១

៤.ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ........ ១២

ក.ការរៀបចំប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ........ ១២

ខ.ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ១៣

គ.រចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ........ ១៣

ឃ.ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ១៦

ង.អង្គប្រតិបត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ........ ១៨

ច.ខ្សែគណនេយ្យភាព ........ ២៣

៥.មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ២៥

ក.គោលការណ៍នៃការផ្ទេរមុខងារ........ ២៦

ខ.ដំណើការផ្ទេរមុខងារ ........ ២៧

គ.មុខងារជាភ្នាក់ងារ ........ ២៩

៦.ចរិកាថ្នាក់ក្រោមជាតិ........ ៣០

## I.ទិដ្ឋភាពទូទៅនៃមាតិកានិងមាតិការងសង្ខេប

### ១.គន្លឹះចងចាំមាតិកា

ដើម្បីស្វែងយល់ពីប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា យើងឃើញថាមានឯកសាជាច្រើនដែលយើងអាចសិក្សាឈ្វេងយល់ និងរៀនសូត្រ ប៉ុន្តែជាបទពិសោធន៍ផ្ទាល់ខ្លួន និងជាអ្នករៀនជំនាញរដ្ឋបាលសាធារណៈម្នាក់ផងយល់ថាឯកសាស្តីពី«**ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា**»ជាឯកសារជាគ្រឹះ និងឯកសាគោលដ៏សំខាន់ដែលអ្នករៀនជំនាញរដ្ឋបាលមិនគួរមើលរំលង និងស្វែងយល់ជាដំបូងគេ។ នេះជាឯកសារបទឧទ្ទេសនាមដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលរៀបរៀងដោយក្រសួងមហាផ្ទៃ នាឆ្នាំ២០១៩។ ដោយមើលឃើញពីសារៈប្រយោជន៍ និងគុណតម្លៃឯកសារនេះ ទើបជម្រុញឱ្យខ្ញុំសាកល្បងសង្ខេប ដោយប្រើទិចនិចផ្ទាល់ខ្លួន ដើម្បីងាយចាំ ងាយយល់ទុកជាការស្វែងយល់ផ្ទាល់ខ្លួនផង និងសម្រាប់ចែករំលែកផង។

ឯកសារស្តីពី«**ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា**» ចែកជា៦មាតិកាសំខាន់ៗគឺ ១).ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ២).ក្របខណ្ឌគោលនយោបាយសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ៣).គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ៤).ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ៥).មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៦).ថវិកាថ្នាក់ក្រោមជាតិ។ ដើម្បីងាយចាំ ខ្ញុំបានបង្កើតជាសំណង់ប្រយោគសម្រាប់ក្តោបមាតិកាទាំងនេះគឺ«ប្រវត្តិ-គោល-គោល-ការរៀបចំ-មុខងារ-ថវិកា»។ ការបង្កើតប្រយោគបែបនេះ គ្រាន់តែជាទិចនិចផ្ទាល់ខ្លួន ដើម្បីកត់ចំណាំពីមេរៀននេះ។ ក្នុងនោះពាក្យនីមួយៗសំដៅ៖

- ប្រវត្តិ-ប្រវត្តិ**អភិបាលកិច្ចមូលដ្ឋាន**នៅកម្ពុជា
- គោល-ក្របខណ្ឌគោលនយោបាយសម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ
- គោល-គោលការណ៍នៃ**ការរៀបចំអភិបាលកិច្ចមូលដ្ឋាន**នៅកម្ពុជា
- ការរៀបចំ-**ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន**នៅកម្ពុជា
- មុខងារ-មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ថវិកា-ថវិកាថ្នាក់ក្រោមជាតិ

ដូច្នេះយើងអាចសង្ខេបយ៉ាងខ្លី និងងាយចំណាំ មេរៀនប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាដោយខ្លីថា **ប្រវត្តិ-គោល-គោល-ការរៀបចំ-មុខងារ-ថវិកា**។

### ២.គន្លឹះចងចាំមាតិការង

យើងនឹងពិនិត្យមើលមេរៀននេះ តើមានមាតិកានិងមាតិការងមានអ្វីខ្លះ? ផ្អែកលើតាមមេរៀននេះបានចែកជា**៦មាតិកា**៖

- ទី១ ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា **មាន៦មាតិការង**
- ទី២ ក្របខណ្ឌគោលនយោបាយសម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ **មាន២មាតិការង**
- ទី៣ គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា **ពុំមាន**
- ទី៤ ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា **មាន៦មាតិការង**
- ទី៥ មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ **មាន៣មាតិការង**
- ទី៦ ថវិកាថ្នាក់ក្រោមជាតិ **ពុំមាន**

ដូច្នេះយើងឃើញថាមាតិកាទី១មាន៦មាតិការង មាតិកាទី២មាន២មាតិការង មាតិកាទី៣ពុំមានមាតិការង មាតិកាទី៤មាន៦មាតិការង មាតិកាទី៥មាន៣មាតិការង និងមាតិកាទី៦ពុំមាតិការង។

វិធីចំណាំមួយទៀតគឺ លេខខាងឆ្វេងជាមាតិកា ចំណែកលេខខាងស្តាំងជាមាតិការងគឺ៖

- ១-៦
- ២-២
- ៣-០
- ៤-៦
- ៥-៣
- ៦-០

## ៣.ពាក្យគន្លឹះគួរស្វែងយល់

ពាក្យគន្លឹះគួរស្វែងយល់ ដើម្បីយល់ស៊ីជម្រៅមេរៀន និងជៀសវាងការយល់ច្រឡំគ្នា ៖

- ការរៀបចំអភិបាលកិច្ចមូលដ្ឋាន(គោលការណ៍)
- ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន
- ការរៀបចំប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីងាយយល់ពីគោលគំនិត និងភាពខុសគ្នារវាងពាក្យទាំងនេះ ខ្ញុំវែកញែកខ្លីៗដូចខាងក្រោម៖

- ☞ ការរៀបចំអភិបាលកិច្ចមូលដ្ឋាន(គោលការណ៍)
  - * ការរៀបចំរដ្ឋបាលឯកភាព
  - * ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ☞ ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន
  - * ការរៀបចំប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ
  - * ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
  - * រចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - * ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - * អង្គប្រតិបត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - * ខ្សែគណនេយ្យភាព
- ☞ ការរៀបចំប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

  ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជា២ប្រភេទគឺ៖
  - * ប្រព័ន្ធរដ្ឋបាលខេត្ត ឬរដ្ឋបាលតំបន់
  - * ប្រព័ន្ធរដ្ឋបាលមូលដ្ឋានរួមមាន ប្រព័ន្ធ២ថ្នាក់ និងប្រព័ន្ធ៣ថ្នាក់
    - ប្រព័ន្ធ២ថ្នាក់៖ ស្រុក ឃុំ និងក្រុង សង្កាត់
    - ប្រព័ន្ធ៣ថ្នាក់៖ រាជធានី ខណ្ឌ សង្កាត់
- ☞ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
  - * ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា
  - * ក្របខណ្ឌគោលនយោបាយសម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ
  - * គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

* ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា
* មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
* ថវិកាថ្នាក់ក្រោមជាតិ

តាមតាមរយៈការញែករែកនេះ គឺដើម្បីពញ្ញាក់អ្នកអាន ឱ្យចាប់អារម្មណ៍យកចិត្តទុកដាក់លើពាក្យទាំងនេះដែលជាពាក្យគន្លឹះក្នុងសិក្សាស្វែងយល់ពីមេរៀននេះបានស៊ីជម្រៅ។ ដើម្បីងាយចាំពីពាក្យគន្លឹះទាំងនេះ ខ្ញុំមានវិធីកត់ចំណាំតាមរបៀបដូចខាងក្រោមនេះគឺ៖

☞ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
* ការរៀបចំអភិបាលកិច្ចមូល(គោលការណ៍)
* ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន
  - ការរៀបចំប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

ឬរបៀបមួយទៀត ដើម្បីកុំឱ្យមានការយល់ច្រឡំពាក្យទាំងនេះ យើងអាចកត់ចំណាំ៖

☞ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
☞ ការរៀបចំ
* អភិបាលកិច្ចមូលដ្ឋាន(គោលការណ៍)
* ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន
* ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

## II.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា

### ១.ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

#### ➭ ក.មុនឆ្នាំ១៩០៨

រចនាសម្ព័ន្ធរដ្ឋបាលបែងចែកជា តំបន់ ខេត្ត និងភូមិ

➭ តំបន់គ្រប់គ្រងដោយស្តេចត្រាញ់ ជាអ្នកមានមុខមាត់ និងកិត្តិយសនៅក្នុងព្រះរាជវាំង

➭ ខេត្តគ្រប់គ្រងដោយចៅហ្វាយស្រុក ឬអភិបាល តាមការតែងតាំង
- ចៅហ្វាយស្រុកមានជំនួយការជា balat, snang, kralapeas

➭ មេស្រុកចាត់ទុកជាអ្នកគ្រប់គ្រងភូមិ
- ជ្រើសរើសដោយអភិបាល ឬចៅហ្វាយស្រុក ដើម្បីប្រមូលពន្ធ និងគ្រប់គ្រងតាមទីកន្លែងនីមួយៗ
- ការអនុវត្តការងារពុំមានវិធានរដ្ឋបាលកំណត់ច្បាស់លាស់
- មេស្រុកភាគច្រើនមិនចេះអក្សរ មិនមានឥទ្ធិពល និងគ្មានអំណាច
- ចូលបំពេញការងារតាមរយៈទំនាក់ទំនងជាមួយស្តេចត្រាញ់ និងចៅហ្វាយស្រុក
- ភូមិមិនមានបុគ្គលភាពគតិយុត្ត និងទ្រព្យសម្បត្តិអ្វីទាំងអស់

#### ➭ ខ.ចន្លោះឆ្នាំ១៩០៨ដល់១៩៥៥

ក្រឹត្យច្បាប់ស្តីពីការរៀបចំរដ្ឋបាលឃុំ ចូលជាធរមាន ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩០៨

➭ ក្រឹត្យច្បាប់នេះប្រែក្លាយ
- ចៅហ្វាយស្រុកបានក្លាយទៅជាចៅហ្វាយខេត្ត
- មេស្រុកបានក្លាយទៅជាមេឃុំ



ខុទ្ទកាល័យ

☞ រចនាសម្ព័ន្ធរដ្ឋបាល
    * ខេត្ត
    * ស្រុក
    * ឃុំ
    * ភូមិ
☞ ភាពខ្វះចន្លោះនៃក្រឹត្យច្បាប់គ្រប់គ្រងឃុំ ១៩០៨
    * ក្រុមប្រឹក្សាមិនអាចបំពេញតួនាទីដោយប្រសិទ្ធភាព
        - ចំនួនច្រើនលើសលុបនៃក្រុមប្រឹក្សា ឃុំខ្លះមានចំនួនក្រុមប្រឹក្សាជាប់រហូត១៥០រូប
        - ការការពារផលប្រយោជន៍សម្ភូហភាព ឬការអភិវឌ្ឍនៅមូលដ្ឋានមិនអាចធ្វើទៅបានល្អប្រសើរដោយសារថវិកាឃុំមិនមានគ្រប់គ្រាន់។

↳ ក្រឹត្យច្បាប់គ្រប់គ្រងឃុំ ឆ្នាំ១៩០៨ បានកែសម្រួល
- បានចូលជាធរមាននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩
- ដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩២០។
- ក្រឹត្យច្បាប់នេះបានបំពេញបន្ថែម និងកែលម្អនូវភាពខ្វះចន្លោះពីះ
    ☞ កំណត់ពីមុខងារ សមត្ថកិច្ចរបស់ឃុំ ប្រព័ន្ធត្រួតពិនិត្យ ការអនុវត្តមុខងារ និងសមត្ថកិច្ចរបស់ឃុំដោយចៅហ្វាយខេត្ត និងប្រជាជនក្នុងឃុំ។
    ☞ បង្កើតឱ្យមានថវិកាឃុំ មេឃុំអាចជ្រើសរើសបុគ្គលិកឱ្យមកជួយធ្វើការ ឬបង្ហាត់បង្រៀនពីការងារដូចជាស្មៀន និងគ្រូបង្រៀនជាដើម ដើម្បីអាចធានាបាននូវដំណើរការជាប្រក្រតីនៃកិច្ចការរបស់ឃុំ
    ☞ មេឃុំមានតួនាទីជាអ្នកធានាចាត់ចែង និងកាន់កាប់បញ្ជីរដ្ឋបាល ថែរក្សាឯកសារ លិខិតស្នាមផ្សេងៗរបស់ឃុំ ដោយមានបុគ្គលិកជាប់កិច្ចសន្យាជួយការងារទូទៅ
    ☞ មុខងារពាក់ព័ន្ធនឹងវិស័យអប់រំសាធារណៈ ត្រូវប្រគល់ឱ្យឃុំជាអ្នកគ្រប់គ្រងដោយប្រើប្រាស់ថវិកា និងប្រភពហិរញ្ញវត្ថុផ្សេងៗរបស់ឃុំ ក្នុងនោះឃុំអាចតែងតាំងគ្រូបង្រៀន ក៏ដូចជាការសាងសងសាលារៀនបន្ថែម។
    ☞ ក្រឹត្យនេះមាន៨ជំពូកដោយកំណត់ះ
        - ការរៀបចំឱ្យចំនួនក្រុមប្រឹក្សាឃុំ តំណាងឱ្យប្រជាជនត្រូវសមាសមាត្រចំនួនភូមិ
        - ចំនួនក្រុមប្រឹក្សាឃុំកំណត់ចាប់ពី៨រូប ទៅ១៦រូប អាស្រ័យទៅតាមទំហំនៃឃុំ
        - មេឃុំរង ឬជំទប់ ត្រូវបង្កើនសម្រាប់ឃុំដែលមានភូមិច្រើនជាង១៨
        - ចែងពីតួនាទី ភារកិច្ច និងកាតព្វកិច្ច និងអត្ថប្រយោជន៍សម្រាប់អាជ្ញាធរឃុំ
        - បញ្ជាក់ពីកាតព្វកិច្ចរបស់ពលរដ្ឋនៅក្នុងឃុំ និងផលប្រយោជន៍ប្រជាជនទទួលបាន
        - ការរៀបចំ ការប្រើប្រាស់ និងការត្រួតពិនិត្យថវិកាមានភាពងាយស្រួល និងសាមញ្ញ

**ការរៀបចំប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ចូលជាធរមាននៅឆ្នាំ១៩២៣**

↳ ក្រឹត្យច្បាប់គ្រប់គ្រងឃុំត្រូវបានកែសម្រួលឡើងវិញក្នុងឆ្នាំ១៩២៥
↳ បានចូលជាធរមានថ្ងៃទី១ ខែមករា ឆ្នាំ១៩២៦។ តាមរយៈក្រឹត្យនេះ
- បញ្ជាក់កាន់តែច្បាស់អំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ មេឃុំ

- ការចូលកាន់តំណែង
- ប្រព័ន្ធគ្រប់គ្រង និងរបៀបរបបការងារនៅរដ្ឋបាលឃុំ
- ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិឃុំ
- ការងារយុត្តាធិការរបស់ឃុំ
    * សម័យនោះក្រុមប្រឹក្សាឃុំហៅថាក្រុមជំនុំឃុំ
        - មេឃុំជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមជំនុំឃុំ
        - មានជំទប់ដែលជ្រើសរើសចេញពីក្រុមជំនុំជាអ្នកជួយការងារដល់មេឃុំ
    * ជារួមតាមរយៈក្រឹត្យឆ្នាំ១៩២៦ បានរៀបចំរដ្ឋបាលឃុំទៅជាប្រព័ន្ធថ្មីគឺៈ
        - ធ្វើឱ្យឃុំក្លាយជាថ្នាក់រដ្ឋបាលជាក់លាក់ក្នុងប្រព័ន្ធរដ្ឋបាលកម្ពុជា
        - ផ្តល់សិទ្ធអំណាច ធនធានកាន់តែច្រើនដល់ឃុំ ដើម្បីអភិវឌ្ឍនៅមូលដ្ឋាន
        - ការយកចិត្តទុកដាក់ពីរដ្ឋបាលកណ្តាលក្នុងការពង្រឹង និងការលើកស្ទួយរដ្ឋបាលឃុំ

➢ ចាប់ពីឆ្នាំ១៩៤៣ ប្រឈមមុខនឹងសង្គ្រាមឈ្លានពាន
- ការបោះឆ្នោតនៅឃុំបានផ្អាកជាបន្តបន្ទាប់
- បានលុបចោលការបោះឆ្នោតទាំងស្រុងនៅឆ្នាំ១៩៤៨
- មេឃុំនិងជំទប់ឃុំ ត្រូវតែងតាំងដោយអភិបាលខេត្ត ដោយមានការយល់ព្រមពីរ៉េស៊ីដង់។

☞ កំណត់ចំណាំ
* ក្រឹត្យច្បាប់គ្រប់គ្រងឃុំ
    - ១៩០៨
    - ១៩១៩
    - ១៩២៦
* ក្រុមជំនុំឃុំ បោះឆ្នោតផ្ទាល់ ៤ឆ្នាំម្តង
    - ១៩០៨-១៩៤៨
* មេឃុំ ជំទប់ តែងតាំងដោយចៅហ្វាយខេត្ត
    - ១៩៤៨-១៩៥៥

## ➢ គ.ចន្លោះឆ្នាំ១៩៥៥ដល់១៩៧៩

នៅឆ្នាំ១៩៥៥ មានសារាចរណែនាំឱ្យរៀបចំការបោះឆ្នោតឡើងវិញ ប៉ុន្តែការអនុវត្ត ពុំសូវទទួលបានលទ្ធផលឡើយ គឺមានលក្ខខណ្ឌគ្រាន់តែជាការបង្គ្រប់កិច្ចតាមច្បាប់។

➢ ពេលនោះ ក្រុមជំនុំបោះឆ្នោតឡើងវិញ ប៉ុន្តែមិនសូវមានការចូលរួម(១៩៥៥-១៩៥៩)

➢ នៅឆ្នាំ១៩៥៩ មានព្រះរាជក្រមតម្រូវឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ
- បានផ្តល់ឱ្យឃុំនូវឋានៈជានីតិបុគ្គលដូចក្នុងឆ្នាំ១៩២៦
- ព្រះរាជក្រមនេះបានដាក់ព្យួរតាមរយៈការធ្វើប្រជាមតិនៅថ្ងៃទី២៩ ខែវិច្ឆិការ ឆ្នាំ១៩៥៩
- មេឃុំ ចៅសង្កាត់ និងជំទប់ តែងតាំងដោយជីការខេត្ត តាមសំណើររបស់អភិបាលស្រុក។
    ☞ មេឃុំ ចៅសង្កាត់ និងជំទប់ តែងតាំងដោយជីការខេត្ត (១៩៥៩-១៩៧០)
    ☞ សមាជជាតិលើកទី២០ នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥

* ពាក្យ សង្កាត់ ត្រូវបានចាប់ផ្ដើមប្រើប្រាស់ ឃុំនៅក្នុងទីក្រុង
* ពាក្យ ចៅហ្វាខេត្ត ក្រុង ស្រុក ក៏ត្រូវផ្លាស់ប្តូរដោយប្រើជំនួសវិញនូវពាក្យ អភិបាល ។

➢ នៅក្នុងរបបសាធារណៈរដ្ឋខ្មែរ
- យោងតាមរដ្ឋធម្មនុញ្ញមាត្រា១១៤ សម្ភូហភាពដែនដីនៃសាធារណៈរដ្ឋគឺសង្កាត់ ខេត្ត និងក្រុង
- វិមជ្ឈការនៅថ្នាក់ក្រោមជាតិមិនអាចអនុវត្តបាន ដោយសារសង្គ្រាមស៊ីវិលការបោះឆ្នោតគ្រប់ថ្នាក់នៅមូលដ្ឋានមិនអាចដំណើរការបាន
- មេឃុំនៅតែបន្តតែងតាំងដោយអភិបាលខេត្ត(១៩៧០-១៩៧៥)

➢ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
- រដ្ឋធម្មនុញ្ញនៃរបបនេះមានតែ២១មាត្រាប៉ុណ្ណោះ
- ខ្លឹមសារភាគច្រើនផ្តោតទៅលើអំណាច យោធា និងអង្គការ
- ទន្ទឹមនេះ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងប្រទេសត្រូវបានបំផ្លាញចោលទាំងស្រុង។

## ឃ.ចន្លោះឆ្នាំ១៩៧៩ដល់១៩៩៣

បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមលើគ្រប់វិស័យ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលផង ត្រូវបានស្តារ និងកសាងឡើងវិញពីចំណុចសូន្យ។

➢ ចុងឆ្នាំ១៩៧៩
- មានក្រសួង ស្ថាប័នចំនួន១២
- ខេត្តចំនួន១៨ និងក្រុងចំនួន២ ត្រូវបានរៀបចំចំណុះក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។

➢ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចូលរួមជាធរមាន។ រដ្ឋធម្មនុញ្ញនេះបានកំណត់ដែនដីរដ្ឋបាលនៅកម្ពុជា
- ដែនដីប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង
- ខេត្តចែកជាស្រុក។ ស្រុកចែកជាឃុំ។
- ក្រុងចែកជាសង្កាត់។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ បានធ្វើការកែសម្រួលបែងចែកទឹកដីដូចខាងក្រោម

➢ ដែនដីនៃប្រទេសកម្ពុជាចែកជាខេត្តនិងក្រុង
- ខេត្តចែកជាទីរួមខេត្ត និងស្រុក
- ទីរួមខេត្តចែកជាសង្កាត់។ ស្រុកចែកជាឃុំ។
- ក្រុងបែងចែកជាខណ្ឌ និងស្រុកជាយក្រុង។ ខណ្ឌបែងចែកជាសង្កាត់។ ស្រុកជាយក្រុងចែកជាឃុំ ដូចជាស្រុកចំណុះខេត្ត។

➢ ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង និងអាណត្តិការងារនៅតាមដែនដីរដ្ឋបាលនីមួយៗ
- មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការរៀបចំតាមរដ្ឋធម្មនុញ្ញ១៩៨១ដែរ
- ប្តូរឈ្មោះពី គណៈកម្មាធិការប្រជាជនបដិវត្តន៍ មកជា គណៈកម្មាធិការប្រជាជនវិញ។

## ➢ ង.ចាប់ឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលត្រូវបានតាក់តែងរៀបចំជាថ្មីបានកំណត់ថា កម្ពុជាជាប្រទេសប្រកាន់យករបបគ្រប់គ្រងតាមបែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី។ រដ្ឋធម្មនុញ្ញនេះបានបែងចែកដែនដីរដ្ឋបាល៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្តនិងក្រុង
- ខេត្តចែកជាស្រុក។ ស្រុកចែកជាឃុំ។
- ក្រុងចែកជាខណ្ឌ។ ខណ្ឌចែកជាសង្កាត់។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ មានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ ក្នុងការរៀបចំប្រព័ន្ធនិងរចនាសម្ព័ន្ធគ្រប់គ្រងប្រទេសឡើងវិញ។ បញ្ហាដំបូងគេគឺ៖

➢ ការសម្របសម្រួលខាងនយោបាយដើម្បីបង្កើតរដ្ឋាភិបាល ដែលត្រូវការសំឡេងគាំទ្រ២/៣ពីរដ្ឋសភា។

- ជាដំណោះស្រាយគណបក្សប្រជាជននិងគណបក្សហ្វ៊ុនស៊ិនប៊ិច បានព្រមព្រៀងគ្នារៀបចំរដ្ឋាភិបាលចម្រុះ។
  - ☞ មានសហនាយករដ្ឋមន្ត្រី និងមានក្រសួងសំខាន់ៗ៣ ដោយដឹកនាំដោយសហរដ្ឋមន្ត្រីមាន
    - ❧ ទីស្តីការគណៈរដ្ឋមន្ត្រី
    - ❧ ក្រសួងការពារជាតិ
    - ❧ និងក្រសួងមហាផ្ទៃ។
    - ❧ ក្រសួងស្ថាប័នក្រៅពីនេះ ក៏ត្រូវបានបែងចែកគ្នាគ្រប់គ្រងក្នុងរដ្ឋាភិបាលចម្រុះ។
  - ☞ ទន្ទឹមនឹងនេះ កងទ័ព នគរបាល មន្ត្រីរដ្ឋបាលស៊ីវិលពីភាគីគណបក្សហ្វ៊ុនស៊ិនប៉ិចដែលមានសំឡេងភាគច្រើនក្នុងសភានិងភាគីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាបានធ្វើសមារណកម្មជាមួយភាគីអតីតរដ្ឋកម្ពុជា ដឹកនាំដោយគណបក្សប្រជាជនជាភាគីដែលមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងគ្របដណ្តប់ ទឹកដីប្រមាណជា៩០% ទៅជាកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីរដ្ឋបាលស៊ីវិលក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយឆ្នាំ១៩៩៣។
- ដោយឡែករដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងឡើងវិញ
  - ☞ ធ្វើការបែងចែកមុខតំណែងអភិបាល អភិបាលរងខេត្ត ក្រុង ក្នុងចំណោមគណបក្សនយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះ
  - ☞ រាជធានីភ្នំពេញ និងខេត្តចំនួន១០ គណបក្សហ្វ៊ុនស៊ិនប៊ិច ទទួលមុខតំណែងជាអភិបាលនិងខេត្តចំនួន១០ទៀត គណបក្សប្រជាជនកម្ពុជាទទួលមុខតំណែងជាអភិបាល។
  - ☞ ការបែងចែកមុខតំណែងអភិបាល អភិបាលរង ក្នុងចំណោមគណបក្សនយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះនេះត្រូវបានបញ្ចប់ នៅចុងអាណត្តិទី២និងដើមអាណត្តិទី៣នៃរដ្ឋសភា។ដោយសារគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សទទួលបានសំឡេងភាគច្រើននៅក្នុងរដ្ឋសភាជាអ្នកទទួលបានមុខតំណែងអភិបាលរាជធានីខេត្តទាំងអស់។

ចំពោះថ្នាក់ស្រុក ខណ្ឌ ឃុំ សង្កាត់ បានកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រង ប៉ុន្តែក្នុងអាណត្តិទី១និងដើមអាណត្តិទី២នៃរាជរដ្ឋាភិបាលចម្រុះ មិនមានការចុះសម្រុងគ្នា ក្នុងការសម្របសម្រួលខាងនយោបាយ ដើម្បីបែងចែកអំណាចនៅថ្នាក់រដ្ឋបាលទាំងនេះឡើយ។

- ការរៀបចំឡើងវិញ បានធ្វើឱ្យរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈជាការគ្រប់គ្រងបែបមជ្ឈការវិញពេលនោះ
  - សាលាខេត្ត សាលាក្រុង ត្រូវស្ថិតនៅជាខ្សែរបណ្តោយរបស់ក្រសួងមហាផ្ទៃ
  - សាលាស្រុក ខណ្ឌ ឃុំ សង្កាត់ ចាត់ទុកជាសាខាឬអង្គភាពមួយរបស់សាលាខេត្ត ឬសាលាក្រុងសាមី។
    - តាមប្រព័ន្ធនេះ រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិមានស្ថានភាពដូចជារដ្ឋបាលចាំផ្ទះតែប៉ុណ្ណោះ។
    - រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិទទួលបានតែប្រាក់បៀវត្សរ៍មន្ត្រី បុគ្គលិកបម្រើការងារតាមសាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងប្រាក់ចំណាយរដ្ឋបាលប្រចាំថ្ងៃតិចតួច ដែលស្ថិតក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។ អាស្រ័យដោយតម្រូវការនៃបែងចែកអំណាចក្នុងក្រសួងមហាផ្ទៃនិងតម្រូវការនៃការរៀបចំឡើងវិញ
      - * រចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ១៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃមុនពេលមានច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ។
      - * ផ្អែកលើអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ៣១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ចនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តក្រុង។
- ស្របពេលរដ្ឋាភិបាលនីតិកាលទី១
  - ត្រូវរ៉ាប់រងដោះស្រាយបញ្ហាប្រឈមនានាជាច្រើន ដែលបន្សល់ទុកដោយសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃនិងរបបប្រល័យពូជសាសន៍ខ្មែរក្រហម
    - ភាគីកម្ពុជាប្រជាធិបតេយ្យដែលជាភាគីហត្ថលេខីមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមិនបានអនុវត្តកិច្ចព្រមព្រៀងនេះ និងមិនបានចូលរួមបោះឆ្នោតជាតិ នាឆ្នាំ១៩៩៣ឡើយ។
    - ភាគីនេះបន្តធ្វើសកម្មភាពប្រដាប់អាវុធប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីការបោះឆ្នោតដើម្បីការពារទឹកដីមួយផ្នែកតូចដែលគេបាន និងកំពុងគ្រប់គ្រងនាពេលនោះ និងប៉ុនប៉ងពង្រីកតំបន់ត្រួតត្រាសំដៅឈានទៅគ្រប់គ្រងប្រទេសឡើងវិញ។
  - ដើម្បីបញ្ចប់សង្គ្រាម នាំមកនូវសន្តិភាពជូនប្រទេសជាតិ សម្តេចហ៊ុនសែន នាពេលនោះជានាយករដ្ឋមន្ត្រីទី២
    - បានផ្តួចផ្តើមគំនិតនិងដាក់ចេញគោលនយោបាយឈ្នះ ឈ្នះ ដោយចាប់ផ្តើមពីភូមិសាស្ត្រ ឱរ៉ាល់បន្តភ្ជាប់ទៅម៉ាឡៃ ប៉ៃលិន សំឡូត កំរៀង សំពៅលូន ភ្នំព្រឹក និងចុងក្រោយទៅអន្លង់វែង ដោយបានធ្វើសមាហរណកម្មទាំងស្រុងនូវកម្លាំងកម្ពុជាប្រជាធិបតេយ្យនាចុងឆ្នាំ១៩៩៨។
    - ចាប់ពីនោះមក ប្រទេសជាតិមានសន្តិភាពពេញលេញ មានការឯកភាពជាតិ ឯកភាពទឹកដីដែលត្រូវបានគ្រប់គ្រងក្រោមដំបូលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣តែមួយ។
  - ក្នុងស្ថានភាពដ៏អំណោយផលនេះ
    - កម្ពុជាមានការតាំងចិត្តខាងនយោបាយយ៉ាងមុតមាំ ដើម្បីរៀបចំចាត់ចែងបោះឆ្នោតជាតិលើកទី២ដោយខ្លួនផ្ទាល់។
    - ផ្អែកលើការតាំងចិត្តនេះ ច្បាប់បោះឆ្នោតជាតិត្រូវបានរៀបចំតាក់តែងឡើងដោយមន្ត្រីកម្ពុជាក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុមួយផ្នែកពីសហគមន៍អន្តជាតិ។

- ☞ ក្រោមច្បាប់បោះឆ្នោតជាតិនេះ ស្ថាប័នឯករាជ្យមួយ ត្រូវបានបង្កើតឡើងសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោតគឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហៅកាត់គ.ជ.ប។ ការបោះឆ្នោតជាតិលើកទី២បានប្រព្រឹត្តទៅតាមអាណត្តិដែលកំណត់ប្រកបដោយជោគជ័យនាខែកក្កដា ឆ្នាំ១៩៩៨។

↳ ទោះបីជាយ៉ាងនេះក្តី គណបក្សក្នុងរាជរដ្ឋាភិបាលចម្រុះនៅតែទាមទារបែងចែកអំណាចនៅ**រដ្ឋបាលស្រុក ឃុំ សង្កាត់ និងនៅតាមភូមិនានា**ទូទាំងប្រទេស។

- ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ
  - ☞ គណបក្សប្រជាជនកម្ពុជាបានផ្តួចផ្តើមឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំសង្កាត់ ដើម្បីក្រសួងប្រកួតប្រជែងការគ្រប់គ្រងឃុំសង្កាត់ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ គំនិតផ្តួចផ្តើមនេះ ត្រូវបានទទួលយក និងគាំទ្រដោយគណបក្សហ្វ៊ុនស៊ិនប៉ិច។
  - ☞ ផ្អែកលើគំនិតផ្តួចផ្តើមនេះ ការសម្របសម្រួលខាងនយោបាយ ដើម្បីរៀបចំក្របខណ្ឌគោលនយោបាយសម្រាប់ការបោះឆ្នោតនៅថ្នាក់ឃុំសង្កាត់ និងការផ្ទេរវិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់រដ្ឋបាលនេះ ត្រូវបានរៀបចំឡើងវិញនាឆ្នាំ១៩៩៩ និងឈានទៅរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័តនាខែមករា ឆ្នាំ២០០១។
  - ☞ នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ទូទាំងប្រទេសត្រូវបានរៀបចំឡើងតាមរយៈគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ចាប់ពីពេលនោះមក កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានធ្វើឡើងនៅថ្នាក់ឃុំសង្កាត់។ សមិទ្ធផលនៃកំណែទម្រង់ដែលសម្រេចបាននៅថ្នាក់ឃុំសង្កាត់ បានជំរុញនិងលើកទឹកចិត្តដល់រាជរដ្ឋាភិបាលដើម្បីពង្រីកដំណើរការកំណែទម្រង់នេះ ដល់គ្រប់ថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយការបោះឆ្នោតនៅថ្នាក់រដ្ឋបាលទាំងនេះត្រូវបានរៀបចំនាឆ្នាំ២០០៩។
- ផ្អែកលើតម្រូវការនៃការកែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីរៀបចំឡើងវិញនូវដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖
  - ☞ ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។
  - ☞ រាជធានីភ្នំពេញចែកជា ខណ្ឌ។ ខណ្ឌចែកជាសង្កាត់។
  - ☞ ខេត្តចែកជាក្រុង និងស្រុក។ ក្រុងចែកជាសង្កាត់។ ស្រុកចែកជាឃុំនិងសង្កាត់។

↳ ការរៀបចំដែនដីតាមការបែងចែកនេះ គឺសំដៅរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឱ្យបានជាក់លាក់រវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ដែលបានអនុវត្តរហូតដល់សព្វថ្ងៃ។

### ច.វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជា

#### ចរន្តនៃអភិបាលកិច្ចមូលដ្ឋាន

- ការធ្វើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា ពុំមែនជាយុទ្ធសាស្ត្រ ឬមធ្យោបាយពិសេសដោយឡែកសម្រាប់តែនៅកម្ពុជានោះឡើយ។
- ចាប់តាំងពីចុងទសវត្សរ៍ទី៩០ វិមជ្ឈការបានក្លាយជាប្រធានបទ និងជាមធ្យោបាយដ៏មានប្រជាប្រិយភាព ដែលត្រូវបានយកទៅអនុវត្តនៅក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតាមបណ្តារប្រទេសនានាជាច្រើន នៅលើពិភពលោករាប់ចាប់តាំងពីតំបន់អាស៊ី អឺរ៉ុប និងអាមេរិកជាដើម។
- ទោះបីជាយ៉ាងនេះក្តី ប្រទេសនីមួយៗអនុវត្តវិមជ្ឈការ ដោយមានមូលហេតុផ្សេងៗគ្នា ផ្អែកទៅតាមកត្តានយោបាយ ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីផ្សេងជាដើម។

#### វិមជ្ឈការជាអ្វី?

- ក្នុងក្របខណ្ឌទូទៅវិមជ្ឈការ ត្រូវបានគេឱ្យនិយមន័យថា ជាដំណើរការមួយដែលសិទ្ធអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈ ត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្តាលទៅឱ្យរដ្ឋាភិបាលមូលដ្ឋាន។ វិមជ្ឈការមានទំនាក់ទំនង យ៉ាងជិតស្និតទៅនឹងគោលគំនិតស្តីពី Subsidiarity ដែលគោលគំនិតនេះបានកំណត់ថា រាល់មុខងារត្រូវបានផ្ទេរទៅឱ្យថ្នាក់ទាបបំផុតណាដែលមានសមត្ថភាពអាចបំពេញមុខងារនោះបាន។

#### អត្ថន័យវិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជា

- វិមជ្ឈការគឺ រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សាថ្នាក់ ក្រោមជាតិដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន។
- វិសហមជ្ឈការគឺ រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន ធ្វើប្រតិភូកម្ម មុខងារសិទ្ធិអំណាច និងធនធាន(ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តមុខងារនោះក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់។

### ២.ក្របខណ្ឌគោលនយោបាយសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ធ្វើការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិចាប់តាំងពីក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣មក។ ជាពិសេសក្រោយពីប្រទេសជាតិមានសន្តិភាព ការឯកភាពជាតិ ឯកភាពទឹកដី តាមរយៈការអនុវត្តដោយជោគជ័យនូវគោលនយោបាយឈ្នះៗ។

- រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់ឃុំសង្កាត់ ដោយធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅទូទាំងប្រទេសនាឆ្នាំ២០០២។
- បន្ទាប់មកនៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានបន្តពង្រីងពង្រីកការអនុវត្តកំណែទម្រង់ការនិងវិសហម្ឈការនៅថ្នាក់ដទៃទៀតនៃរដ្ឋបាលថ្នាក់ក្រោមជតិ តាមរយៈការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេស។
- រាជរដ្ឋបាលអនុវត្តកំណែទម្រង់នេះដោយមានការប្រុងប្រយ័ត្ននិងធ្វើឡើងជាជំហានៗតាមរយៈការធ្វើបណ្តើរដកបទពិសោធន៍បណ្តើរ និងពង្រឹងពង្រីកបណ្តើរ។

### ក.យុទ្ធសាស្ត្រចតុកោណនិងយុទ្ធសាស្ត្របញ្ចកោណ

នៅក្នុងការអនុវត្តជាជំហានៗនូវកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាបានតាក់តែងនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាជាច្រើន ដែលក្នុងនោះរួមមានក្របខណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាជាច្រើន ដែលក្នុងនោះរួមមានក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌច្បាប់សំខាន់ៗ៖

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ ទី៤ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១
- ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់
- ច្បាប់ស្ដីពីការគ្រប់គ្រងរាជធានីខេត្តក្រុងស្រុកខណ្ឌ
- ច្បាប់ស្ដីពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជខេត្ត ក្រុងស្រុកខណ្ឌ

**ទន្ទឹមនឹងការដាក់ចេញគោលនយោបាយនិងក្របខណ្ឌច្បាប់ខាងលើ រាជរដ្ឋាភិបាលក៏បានរៀបចំកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ។**

- កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលការអនុវត្តកម្មវិធីជាតិនេះ ត្រូវបានចែកជាចេញជាបីដំណាក់កាលតាមរយៈការរៀបចំឱ្យមានផែនការអនុវត្តន៍លម្អិតតាមដំណាក់កាលនីមួយៗ។

### ខ.ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិជ្ឈការនិងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

## ៣.គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

មាត្រា២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ បានចែងថា រាជធានីខេត្តក្រុងស្រុកខណ្ឌត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ មាត្រានេះបានផ្ដល់នូវគោលការណ៍សំខាន់២ក្នុងការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់រាជធានីខេត្តក្រុងស្រុកខណ្ឌ។ ទីមួយគឺការរៀបចំ**រដ្ឋបាលឯកភាព** និងទី២ការធានាបាននូវចីរភាពនៃ**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** នៅថ្នាក់រដ្ឋបាលទាំងនេះរួមមានទាំងរដ្ឋបាលឃុំសង្កាត់។

**រដ្ឋបាលឯកភាព**

- ជាការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ក្រុមប្រឹក្សាម្ចាស់ការក្នុងការគ្រប់គ្រងចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន
  - ក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្ដល់សេវាកម្មនិង ការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួមទាំង

ការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

### គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ភាពជាតំណាងសាធារណៈ
  - ក្រុមប្រឹក្សាត្រូវអនុវត្តការងារក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
-ស្វ័យភាពរបស់មូលដ្ឋាន
  - ស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការដែលបានប្រគល់ ឬធ្វើប្រតិភូកម្មឱ្យដោយច្បាប់ប្រកបដោយប្រសិទ្ធភាព។
- ការពិគ្រោះយោបល់ និងការចូលរួម
  - ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវៈជួប និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានលើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ចដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។
- ការឆ្លើយតប និងគណនេយ្យភាព
  - ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
  - សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាពលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចលើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋមូលដ្ឋាន។
- ការលើកស្ទួយសមធម៌
  - ការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច។
- តម្លាភាព និងសុចរិតភាព
  - គឺជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព និងច្បាប់ ក្នុងលក្ខណៈបើកចំហ តម្លាភាព ការចូលរួម និងឆ្លើយតប។
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច
  - គឺជាការប្រកាន់យកនូវវិធាននៃច្បាប់ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច។

### ៤.ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

#### ក.ការរៀបចំប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

- ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០២ និងក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌឆ្នាំ ២០០៩
  - រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងវិញ
  - ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរាជធានីខេត្តក្រុងស្រុកខណ្ឌ
    - បច្ចុប្បន្នប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជា២ប្រភេទគឺ៖
      - * ប្រព័ន្ធរដ្ឋបាលខេត្ត ដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់
      - * ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ដែលរួមមាន ប្រព័ន្ធ២ថ្នាក់ និងប្រព័ន្ធ៣ថ្នាក់
        - ប្រព័ន្ធ២ថ្នាក់៖ ស្រុក ឃុំ និងក្រុង សង្កាត់
        - ប្រព័ន្ធ៣ថ្នាក់៖ រាជធានី ខណ្ឌ សង្កាត់
  - រដ្ឋបាលខេត្តប្រទេសភាគច្រើនហៅថា រដ្ឋបាលតំបន់ មានមុខងារសំខាន់៣គឺ៖
    - អនុវត្តមុខងារជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួងស្ថាប័ននៅថ្នាក់ជាតិ
    - អនុវត្តមុខងាររបស់ថ្នាក់ជាតិ
    - អនុវត្តមុខងារក្នុងការផ្តល់សេវានិងការអភិវឌ្ឍ
  - រដ្ឋបាលមូលដ្ឋាន គឺជារដ្ឋបាលដែលនៅកៀក ឬនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋដែលមានលទ្ធភាព សមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍបានឆាប់រហ័សជាងថ្នាក់ជាតិ មានប្រសិទ្ធភាពនិងមានភាពឆ្លើយតប ជាងថ្នាក់ជាតិ ចំពោះសេចក្តីរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានខុសៗគ្នា។

#### ខ.ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

- មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- មាត្រា២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
  - កំណត់ឱ្យរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ រួមមានដែនដី និងប្រជាពលរដ្ឋ នៅក្នុងដែនដីនោះ និងមានក្រុមប្រឹក្សាមួយជាតំណាង។
  - ការផ្តល់ភាពជានីតិបុគ្គល ចំពោះរដ្ឋបាលរាជធានីខេត្ត ក្រុងស្រុកខណ្ឌ និងឃុំសង្កាត់ គឺក្នុងគោលបំណងផ្តល់ សិទ្ធអំណាច មុខងារ ធនធាន និងទ្រព្យសម្បត្តិឱ្យដល់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាអាចគ្រប់គ្រង ចាត់ចែង កិច្ចការនានានៅមូលដ្ឋាន សំដៅឆ្លើយតបនឹង តម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងអភិវឌ្ឍ មូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព សមធម៌ និងបរិយាបន្ន។

#### គ.រចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ និងលិខិតបទដ្ឋាន អនុវត្តបានតម្រូវឱ្យក្រុមប្រឹក្សានីមួយៗ រៀបចំឱ្យមានអង្គភាពមួយចំនួននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនដើម្បី ក្រុមប្រឹក្សាអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពតាមច្បាប់ និងលិខិតបទដ្ឋានកំណត់។

- រចនាសម្ព័ន្ធរដ្ឋបាលរាជធានីមានអង្គភាព និងយន្តការក្រោមឱវាទ ដូចខាងក្រោម៖
  - ក្រុមប្រឹក្សា
  - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម
- គណៈកម្មាធិការនានា
- ការិយាល័យប្រជាពលរដ្ឋ
- គណៈអភិបាល
  - នាយក-នាយករងរដ្ឋបាល
  - ទីចាត់ការរដ្ឋបាល
  - ទីចាត់ការផែនការនិងវិនិយោគ
  - ទីចាត់ការហិរញ្ញវត្ថុ
  - ទីចាត់ការរៀបចំក្រុង
  - ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
  - ទីចាត់ការអន្តរវិស័យ
  - ទីចាត់ការកិច្ចការច្បាប់និងសិទ្ធមនុស្ស
  - ទីចាត់ការគ្រប់គ្រងកាកសំណល់
  - ទីចាត់ការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តជាតិ
  - អង្គភាពលទ្ធកម្ម
  - អង្គភាពច្រកចេញចូលតែមួយ
  - មន្ទីសុខាភិបាល(អនុក្រឹត្យ១៩៣/២០១៩)

➢ រចនាសម្ព័ន្ធរដ្ឋបាលខេត្តមានអង្គភាព និងយន្តការក្រោមឱវាទដូចខាងក្រោម៖

- ក្រុមប្រឹក្សា
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម
- គណៈកម្មាធិការនានា
- ការិយាល័យប្រជាពលរដ្ឋ
- គណៈអភិបាល
  - នាយក-នាយករងរដ្ឋបាល
  - ទីចាត់ការរដ្ឋបាល
  - ទីចាត់ការផែនការនិងវិនិយោគ
  - ទីចាត់ការហិរញ្ញវត្ថុ
  - ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
  - ទីចាត់ការអន្តរវិស័យ
  - ទីចាត់ការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តជាតិ(ខេត្តព្រះសីហនុខេត្តសៀមរាប)
  - អង្គភាពលទ្ធកម្ម

- ☞ អង្គភាពច្រកចេញចូលតែមួយ
- ☞ មន្ទីរសុខាភិបាល(អនុក្រឹត្យ១៩៣/២០១៩)

↳ រចនាសម្ព័ន្ធរដ្ឋបាលក្រុង ដូចខាងក្រោម៖

- ~ ក្រុមប្រឹក្សា
- ~ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ~ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- ~ គណៈកម្មាធិការលទ្ធកម្ម
- ~ គណៈកម្មាធិការនានា
- ~ ការិយាល័យប្រជាពលរដ្ឋ
- ~ គណៈអភិបាល
  - ☞ នាយក-នាយករងរដ្ឋបាល
  - ☞ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
  - ☞ ការិយាល័យគ្រប់គ្រងធនធានមនុស្ស
  - ☞ ការិយាល័យផែនការ និងគាំទ្រសង្គាត់
  - ☞ ការិយាល័យលេខាធិការក្រុមប្រឹក្សា
  - ☞ ការិយាល័យអប់រំ យុវជន និងកីឡា
  - ☞ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
  - ☞ ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
  - ☞ ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សារធារណៈ
  - ☞ ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
  - ☞ ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម
  - ☞ ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
  - ☞ ការិយាល័យច្រកចេញចូលតែមួយ
  - ☞ អង្គភាពលទ្ធកម្ម

↳ រចនាសម្ព័ន្ធរដ្ឋបាលស្រុកដូចខាងក្រោម៖

- ~ ក្រុមប្រឹក្សា
- ~ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ~ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- ~ គណៈកម្មាធិការលទ្ធកម្ម
- ~ គណៈកម្មាធិការនានា
- ~ ការិយាល័យប្រជាពលរដ្ឋ
- ~ គណៈអភិបាល
  - ☞ នាយក-នាយករងរដ្ឋបាល
  - ☞ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

- ☞ ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ☞ ការិយាល័យផែនការ និងគាំទ្រសង្កាត់
- ☞ ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ☞ ការិយាល័យអប់រំ យុវជន និងកីឡា
- ☞ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ☞ ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ☞ ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន
- ☞ ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ☞ ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម
- ☞ ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ☞ ការិយាល័យច្រកចេញចូលតែមួយ
- ☞ អង្គភាពលទ្ធកម្ម

➥ **រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ ដូចខាងក្រោម៖**

- ~ ក្រុមប្រឹក្សា
- ~ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- ~ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- ~ គណៈកម្មាធិការលទ្ធកម្ម
- ~ គណៈកម្មាធិការនានា
- ~ ការិយាល័យប្រជាពលរដ្ឋ
- ~ គណៈអភិបាល
    - ☞ នាយក-នាយករងរដ្ឋបាល
    - ☞ ការិយាល័យរដ្ឋបាល និងបុគ្គលិក
    - ☞ ការិយាល័យផែនការ និងហិរញ្ញវត្ថុ
    - ☞ ការិយាល័យលេខាធិការក្រុមប្រឹក្សា
    - ☞ ការិយាល័យអប់រំ យុវជន និងកីឡា
    - ☞ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
    - ☞ ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
    - ☞ ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
    - ☞ ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
    - ☞ ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម
    - ☞ ការិយាល័យច្រកចេញចូលតែមួយ
    - ☞ អង្គភាពលទ្ធកម្ម

## ឃ.ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### ការជ្រើសរើសសមាជិកក្រុមប្រឹក្សា

- ជាគោលការណ៍ច្បាប់, រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលកំណត់ ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា«ក្រុមប្រឹក្សា»។
- ក្រុមប្រឹក្សានេះមានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មី ចូលកាន់តំណែងហើយ អាណត្តិនោះត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។
- ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សានីមួយៗ ធ្វើឡើងតាមរយៈការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រ។ គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោត ត្រូវដាក់បញ្ជីឈ្មោះបេក្ខជនសមាជិកក្រុមប្រឹក្សាស្រប តាមនីតិវិធីជាធរមាន ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬសមាជិកក្រុមប្រឹក្សាក្នុងនាមប្រជាពលរដ្ឋត្រូវបោះឆ្នោតជ្រើសរើសគណបក្សដែលខ្លួនពេញចិត្ត។ ចំនួនអាសនៈគណបក្សនយោបាយនីមួយៗទទួលបានគឺអាស្រ័យលើសំឡេងឆ្នោតដែលគណបក្សនយោបាយ នោះទទួលបានដោយធ្វើការបែងចែកអាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុត។
    - ក្រុមប្រឹក្សានីមួយៗ៖
        - ត្រូវមានប្រធានម្នាក់ ដោយប្រធានគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។
        - ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ។
        - ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិច១២០ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីគ្មានអនុក្រឹត្យថែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗត្រូវយកតាមចំនួនសរុបចុងក្រោយ នៃក្រុមប្រឹក្សាអាណត្តិចាស់។
        - ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមជាប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
        - ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
        - ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានាដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

- ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ
    - ☞ រាជធានីភ្នំពេញ
        - ក្រុមប្រឹក្សារាជធានីភ្នំពេញ ២៧រូប
        - ក្រុមប្រឹក្សាខណ្ឌ ១១ ទៅ ២១រូប
        - ក្រុមប្រឹក្សាសង្កាត់ ០៥ ទៅ ១១រូប
    - ☞ ខេត្តក្រុងស្រុកខណ្ឌ
        - ក្រុមប្រឹក្សាខេត្ត ១៥ ទៅ ២៧រូប
        - ក្រុមប្រឹក្សាក្រុង ១១ ទៅ ២១រូប
        - ក្រុមប្រឹក្សាស្រុក ១១ ទៅ ២១រូប
        - ក្រុមប្រឹក្សាឃុំ០៥ ទៅ ១១រូប
        - ក្រុមប្រឹក្សាសង្កាត់០៥ ទៅ ១១រូប

### ➢ តួនាទីនិងសិទ្ធអំណាចរបស់ក្រុមប្រឹក្សា

- តួនាទីនិងសិទ្ធអំណាចរបស់ក្រុមប្រឹក្សា
    - ☞ មានតួនាទីក្រុមប្រឹក្សា
        - គ្រប់គ្រង និងចាត់ចែង រាល់កិច្ចការនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
        - បំពេញមុខងារតាមច្បាប់ដែលបានប្រគល់ និងប្រតិភូកម្ម
    - ☞ សិទ្ធអំណាចរបស់ក្រុមប្រឹក្សា
        - ធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ
        - ធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ

## ➢ ង.អង្គប្រតិបត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### ➢ គណៈអភិបាល

- ការបង្កើតគណៈអភិបាល និងអាណត្តិគណៈអភិបាល
    - ☞ គណៈអភិបាលកើតចេញពីការតែងតាំង
    - ☞ អាណត្តិមិនលើសពី៤ឆ្នាំ
    - ☞ អភិបាល និងអភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សា
- សមាសភាពគណៈអភិបាល
    - ☞ គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើន១១រូប
    - ☞ គណៈអភិបាលខេត្តមានចំនួនពី ៧រូប ទៅ ១១រូប
    - ☞ គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពី ៥រូបទៅ៧រូប
- គណៈអភិបាលមានតួនាទីនិងភារកិច្ចដោយសង្ខេបគឺ
    - ☞ សិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានា
        - ពាក់ព័ន្ធនឹងសិទ្ធអំណាចខាងបញ្ញត្តិ និងសិទ្ធអំណាចខាងប្រតិបត្តិ
        - ដើម្បីក្រុមប្រឹក្សាពិភាក្សានិងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ
    - ☞ តួនាទីជាតំណាងក្រសួងស្ថាប័ន

- (ក្រុមប្រឹក្សា)តំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល
    - ៚ ក្នុងការណែនាំ សម្របសម្រួល តម្រង់ទិស មន្ទីរអង្គភាពខ្សែរបណ្ដោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
- អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួងស្ថាប័ន
    - ៚ ពាក់ព័ន្ធ ក្នុងការងារសន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់និងសិទ្ធមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- គណៈអភិបាលមានតួនាទី ភារកិច្ចចម្បងៗជាសម្រាយបន្ថែមគឺដូចខាងក្រោមៈ
  - ☞ សិក្សាស្រាវជ្រាវ ដើម្បីផ្ដល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានា
    - ពាក់ព័ន្ធនឹងសិទ្ធអំណាចខាងបញ្ញត្តិនិងសិទ្ធអំណាចខាងប្រតិបត្តិ
    - ដើម្បីក្រុមប្រឹក្សាពិភាក្សានិងអនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញទាក់ទងៈ
    - ↳ ការពិនិត្យមុខងារដែលបានប្រគល់ឬបានផ្ទេរ
      - របៀបរបបនិងបែបបទ
      - នីតិវិធីនៃការអនុវត្តមុខងារ
      - ភារកិច្ចនិងការចាត់ចែងធនធាន
    - ↳ ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន
      - ទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរ
      - ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ
    - ↳ ផែនការ
      - ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ
      - កម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំ
      - ក្របខណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពរាល់ឆ្នាំ
      - គម្រោងថវិកាប្រចាំឆ្នាំ
    - ↳ ទីចាត់ការនិងការិយាល័យ
      - ការបង្កើត និងការកែសម្រួល
      - ឬការរំសាយទីចាត់ការ
      - ឬការិយាល័យនានា
    - ↳ ការងារបុគ្គលិក
      - ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
      - ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក
      - ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សា

- ការបង្កើត ការកំណត់នីតិវិធី ការបង្កើត និងការរៀបចំផ្សេងៗ
  - ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការនិងបុគ្គលិកក្រុមប្រឹក្សា
  - ការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា
  - ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សា
  - ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណៈ ដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មានលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច
  - កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

- តួនាទីជាតំណាងក្រសួងស្ថាប័ន
  - តំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល
    - ក្នុងការណែនាំ សម្របសម្រួល តម្រង់ទិស មន្ទីរអង្គភាពខ្សែរបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។
  - អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួងស្ថាប័ន
    - ពាក់ព័ន្ធ ក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់និងសិទ្ធមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- អភិបាលរាជធានី ខេត្តក្រុងស្រុកខណ្ឌ អនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួងស្ថាប័ន លើកិច្ចការដូចខាងក្រោម៖
  - ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
    - លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធមនុស្ស ចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
  - ធ្វើជាប្រធានគណៈបញ្ជាការឯកភាពក្នុងការដឹកនាំសម្របសម្រួលមន្ទី ការិយាល័យ អង្គភាពពាក់ព័ន្ធនានា
    - ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងដែនសមត្ថកិច្ច
  - ណែនាំដល់មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័ន
    - ដែលប្រចាំនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទី ការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ។
  - សម្របសម្រួលតម្រង់ទិស

- មន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងដែនសមត្ថកិច្ច ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។
- ករណីមានកិច្ចការពាក់ព័ន្ធច្រើនវិស័យ អភិបាលត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ ការិយាល័យ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងតម្រូវការអាទិភាពរបស់មូលដ្ឋាន។

➢ ធ្វើការណែនាំជាបន្ទាន់

- ដល់ប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ននានាដែលបំពេញការងារនៅក្នុងដែនដីរបស់ខ្លួនឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់ នៅពេលពិនិត្យឃើញមានភាពមិនប្រក្រតីក្នុងមន្ទីរការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយ ឬមានការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ ការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយ

➢ រាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី

- មន្ទីរការិយាល័យ អង្គភាព និងទីភ្នាក់ងារសាមី ក្នុងករណីដែលប្រធានមន្ទីរ អង្គភាព ការិយាល័យ និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ។

➢ មានសិទ្ធស្នើជាលាយលក្ខណ៍អក្សទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន

- ដើម្បីដកហូតពីមុខតំណែងប្រធានមន្ទីរ ការិយាល័យ អង្គភាព ឬអ្នកទទួលខុសត្រូវភ្នាក់ងារណា ដែលប្រព្រឹតខុសឆ្គង ហើយមិនអាចធ្វើយុត្តិកម្មបាន

➢ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល

- ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

## ➢ មេឃុំ ចៅសង្កាត់

- នៅសាលាឃុំសង្កាត់ បុគ្គលិកក្របខណ្ឌមានស្មៀនឃុំសង្កាត់មួយរូបតែប៉ុណ្ណោះ។

☞ ស្មៀនឃុំសង្កាត់

- ជាមន្ត្រីរាជការក្របខណ្ឌក្រសួងមហាផ្ទៃ
- តែងតាំងឱ្យទៅបំពេញការងារនៅសាលាឃុំ សាលាសង្កាត់
- ដើម្បីជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំសង្កាត់។
- ករណីមានការសម្រេចពីក្រុមប្រឹក្សាឃុំសង្កាត់ មេឃុំ ចៅសង្កាត់អាចស្នើ ផ្លាស់ប្តូរស្មៀនឃុំសង្កាត់បាន។

☞ ឃុំសង្កាត់មានសិទ្ធ

- ជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដែលជាបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ
- ដើម្បីជួយកិច្ចការរបស់ខ្លួនតាមការចាំបាច់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងអាណត្តិ
- អាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិបន្ទាប់។

## ➢ គណៈអភិបាលរាជធានី ខេត្ត ក្រុងស្រុកខណ្ឌ

- ក្រៅពីគណៈអភិបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ រដ្ឋបាលនីមួយៗ
  - មានបុគ្គលិកផ្សេងទៀតដែលត្រូវ មានគណនេយ្យភាពតាមឋានានុក្រមចំពោះក្រុមប្រឹក្សារបស់ខ្លួន។
  - បុគ្គលិកទាំងនោះ មានតួនាទីផ្ដល់ការគាំទ្រផ្នែកច្បាប់ រដ្ឋបាល បច្ចេកទេស និងការគាំទ្រផ្សេងៗទៀត ដល់គណៈអភិបាល ដើម្បីធានាឱ្យគណៈអភិបាលអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកដោយប្រសិទ្ធភាព ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។
  - បុគ្គលិកទាំងនេះ រួមមានបីប្រភេទដូចខាងក្រោមៈ
    - បុគ្គលិកដែលតែងតាំងដោយក្រុមប្រឹក្សា
    - បុគ្គលិកដែលតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា
    - បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា

## ➢ បុគ្គលិកប្រភេទទីមួយ

- គឺជាបុគ្គលិកដែលជ្រើសរើសក្នុងលក្ខណៈប្រកួតប្រជែង បើកចំហរ និងមានតម្លាភាព
- ផ្អែកតាមតម្រូវការចាំបាច់ ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ
- ស្របតាមគោលការណ៍នៃលក្ខន្តិកដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ➢ បុគ្គលិកក្រុមប្រឹក្សាប្រភេទទីពីរ

- ជាបុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា ក្នុងនោះមានគណៈអភិបាល និងនាយករដ្ឋបាល។
- ការតែងតែងតាំងគណៈអភិបាលឱ្យទៅបម្រើការងារជាមួយក្រុមប្រឹក្សា ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ និងលក្ខណសម្បត្តិដូចមានរៀបរាប់ខាងលើ។
- ការតែងតាំងនាយករដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
  - * នាយករដ្ឋបាល
  - មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាលនិងធានានិរន្តភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន
  - ជាអ្នកធានាឱ្យអង្គភាព និងបុគ្គលិកដែលបំពេញការងារនៅតាមអង្គភាពនានាចំណុះសាលារាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ អនុវត្តដោយប្រសិទ្ធភាពនូវសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។

## ➢ បុគ្គលិកក្រុមប្រឹក្សាប្រភេទទីបី

- ជាបុគ្គលិកដែលត្រូវបានផ្ទេទៅឱ្យក្រុមប្រឹក្សានៅពេលដែលមុខងារនៅថ្នាក់ក្រោមជាតិត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិស្របតាមបញ្ញត្តិនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុង ស្រុកខណ្ឌ។
- ក្រៅពីនេះ ក៏មានបុគ្គលិកដែលត្រូវបានធ្វើសមាហរណកម្មឡើងវិញ ទៅក្នុងរចនាសម្ព័ន្ធថ្មីនៃសាលារាជធានីខេត្តក្រុងស្រុកខណ្ឌ បន្ទាប់ពីក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្តក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ដែលត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតបានចូលកាន់តំណែងរបស់ខ្លួននៅតាមរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌនីមួយៗនៅក្នុងឆ្នាំ២០០៩។

- ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើសេចក្តីសម្រេចនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងចាត់ចែងបុគ្គលិក
  - ស្របតាមបទប្បញ្ញត្តិស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះមានការធ្វើសេចក្តីសម្រេចអំពីការតែងតាំង ការបញ្ចេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតសម្រាប់បុគ្គលិករបស់ខ្លួន។
  - ពាក់ព័ន្ធការងារនេះ នៅឆ្នាំ២០១៣
    - រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវអនុក្រឹត្យ៩៩៧ អនក្រ.បក ចុះថ្ងៃទី៦ ខែវិច្ឆិការ ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលបំពេញការងារនៅថ្នាក់ក្រោមជាតិ។
    - បន្ទាប់ពីនោះ ដើម្បីគាំទ្រការអនុវត្តអនុក្រឹត្យខាងលើ ក្រសួងមុខងារសាធារណៈបានដាក់ចេញនូវសេចក្តីណែនាំលេខ ២២០២ មសសណន ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។
  - នៅក្នុងឆ្នាំ២០១៦
    - ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិកនៅថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសដាក់ឱ្យប្រើ ក្នុងគោលបំណងផ្តល់សិទ្ធអំណាចដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងចាត់ចែងបុគ្គលិករបស់ខ្លួន។
  - ទន្ទឹមនេះ នៅចុងឆ្នាំ២០១៧
    - រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ ២៤០ អនក្រ បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធអំណាចទៅឱ្យគណៈអភិបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ ក្នុងការគ្រប់គ្រងបុគ្គលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
    - បាននិរាករណ៍នូវអនុក្រឹត្យលេខ ៩៩៧(២០១៣)។
  - តាមស្មារតីនៃអនុក្រឹត្យនេះ
    - គណៈអភិបាលរាជធានីខេត្ត ក្រុងស្រុកខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនទទួលបានប្រតិភូមកម្មសិទ្ធអំណាចពីរាជរដ្ឋាភិបាល ក្នុងការចេញដីការតែងតាំង និងបញ្ចប់មុខតំណែងមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងៈ
      - ចាប់ពីនាយករងរដ្ឋបាលចុះ សម្រាប់មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ
      - មុខតំណែងចាប់ពីអនុប្រធានមន្ទី ឬអនុប្រធានអង្គភាពប្រហាក់ប្រហែលចុះ
      - សម្រាប់មន្ត្រីរាជការស៊ីវិលនៃមន្ទី អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់រក្រោមជាតិ។
      - ដោយឡែក សម្រាប់មុខតំណែងជាប្រធានមន្ទីឬប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល អភិបាលរាជធានី ខេត្ត អាចលើកសំណើទៅរដ្ឋមន្ត្រីសាមី ដើម្បីស្នើតែងតាំង ឬបញ្ចប់មុខតំណែង។
- នាយករដ្ឋបាល

- ☞ ក្រុមប្រឹក្សា និងគណៈអភិបាលមាននាយករដ្ឋបាល០១រូប ជាជំនួយការ
- ☞ តែងតាំងដោយប្រកាសរបស់ក្រសួងមហាផ្ទៃ
- ☞ នាយករដ្ឋបាល ត្រូវមាននាយករងជាជំនួយការ
  - ~ នាយករងរដ្ឋបាល៩រូប(រាជធានីភ្នំពេញ)
  - ~ នាយករងរដ្ឋបាល៦រូប(ខេត្ត)
  - ~ នាយករងរដ្ឋបាលក្រុង ស្រុក ខណ្ឌ៣រូប

### ច.ខ្សែគណនេយ្យភាព

ការផ្តល់ភាពជាតំណាងសាធារណៈ ដល់ក្រុមប្រឹក្សាតាមរយៈការបោះឆ្នោតនៅថ្នាក់ក្រោមជាតិបានធ្វើឱ្យផ្លាស់ប្តូរខ្សែគណនេយ្យភាពក្នុងការបំពេញកាងារនៅរដ្ឋបាលគ្រប់ថ្នាក់ក្រោមជាតិ។ ពីមុនមានតែសាលារាជធានីខេត្តប៉ុណ្ណោះ តែលត្រូវមានគណនេយ្យភាពចំពោះថ្នាក់ជាតិក្នុងការបំពេញការងាររបស់ខ្លួន។ ប៉ុន្តែតាមរយៈកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការងារនានា ក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានទំនាក់ទំនងគណនេយ្យភាព៣ប្រភេទដូចខាងក្រោម៖

- ➥ ទីមួយ គឺជាគណនេយ្យភាពពីលើចុះក្រោម(គណនេយ្យភាពចំពោះប្រជាពលរដ្ឋ)
  - ~ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋពីព្រោះ
    - ☞ ក្រុមប្រឹក្សានីមួយៗនៅថ្នាក់ក្រោមជាតិ គឺជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ
    - ☞ ជាអ្នកដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់
    - ☞ ក្នុងន័យនេះ ក្រុមប្រឹក្សានីមួយៗនៅគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
      - ~ ចាំបាច់ត្រូវគិតគូរ និងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួន
      - ~ ដើម្បីធានាឱ្យការសម្រេចរបស់ក្រុមប្រឹក្សាអាចឆ្លើយតបបានជាអតិបរមាទៅនឹងសេចក្តីត្រូវការនានាពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួន
      - ~ ដើម្បីធានាឱ្យការសម្រេចរបស់ក្រុមប្រឹក្សាអាចឆ្លើយតបបានជាអតិបរមាទៅនឹងសេចក្តីត្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋទូទៅនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយតម្លាភាព សមធម៌និងបរិយាប័ន្ន។
- ➥ ទីពីរ គឺជាគណនេយ្យភាពពីក្រោមឡើងលើ(គណនេយ្យភាពចំពោះថ្នាក់ក្រោមជាតិ)
  - ~ រដ្ឋបាលនីមួយៗ
    - ☞ ត្រូវបានផ្តល់នូវស្វ័យភាព និងសិទ្ធអំណាចក្នុងការគ្រប់គ្រង និងចាត់ចែងធនធានរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋនិងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនយ៉ាងណាក្តី ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ នៅតែមានគណយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួងស្ថាប័ន។
    - ☞ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ពុំមានអធិបតេយ្យដោយឡែកនៅក្រៅការគ្រប់គ្រងនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋនោះឡើយ។ ក្រុមប្រឹក្សានីមួយៗមានកាតព្វកិច្ចត្រូវគោរពទោតាមគោលការណ៍ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាដែលកំណត់ដោយក្រសួង ស្ថាប័ននានា។

☞ ក្នុងន័យនេះ រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ

- នឹងធ្វើការត្រួតពិនិត្យនីត្យានុកូលភាពលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា រាល់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមាន។
- ក្នុងករណីពិនិត្យឃើញការអនុវត្តការងាររបស់ក្រុមក្រុមប្រឹក្សានៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលនោះកែលម្អឡើងវិញ។
- ក្នុងករណីដែលក្រុមប្រឹក្សានៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះ ហើយធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឡើងវិញ (មាត្រា២៤ និង២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ)។

☞ ទន្ទឹមនេះ អភិបាលរាជធានី ខេត្តក្រុងស្រុកខណ្ឌ មេឃុំ និងចៅសង្កាត់

- ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ក្នុងការបំពេញតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

↳ ទីបី ជាគណនេយ្យភាពផ្ទៃក្នុងនៅក្នុងក្របខណ្ឌនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

- នេះគឺជាការទំនាក់ទំនងរវាងអ្នកធ្វើសេចក្តីសម្រេចដែលកើតឡើងពីការបោះឆ្នោត(ក្រុមប្រឹក្សា)និងអង្គប្រតិបត្តិ។

☞ ក្នុងនាមជាអ្នកអនុវត្តរាល់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាគណៈអភិបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សា។

☞ ក្នុងន័យនេះ ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យមើលរាល់ការអនុវត្តការងាររបស់គណៈអភិបាល

- ដើម្បីធានាថារាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានយកទៅអនុវត្តបានត្រឹមត្រូវពេញលេញ និងប្រកបដោយប្រសិទ្ធភាព
- ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនិងដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន សំដៅលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

☞ ទន្ទឹមនេះ ក្នុងគោលបំណងពង្រឹងគណនេយ្យភាពរបស់គណៈអភិបាល ចំពោះក្រុមប្រឹក្សាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ(មាត្រា១៥២) បានផ្តល់ដល់ក្រុមប្រឹក្សានូវសិទ្ធក្នុងការស្នើទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញមុខពីតំណែងក្នុងករណីអភិបាល អភិបាលរង៖

- បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬអភិបាលរង
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ

### ៥.មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ជាគោលការណ៍ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺសំដៅដល់កិច្ចដំណើរការផ្ទេរមុខងារសិទ្ធអំណាច និងធនធានសមស្រប ទៅឱ្យស្ថាប័ន ឬអង្គភាព ដែលត្រូវបានធ្វើវិមជ្ឈការនោះ។ ក្នុងន័យនេះ ច្បាប់ស្តីពីការគ្រប់គ្រប់រដ្ឋបាល

រាជធានីខេត្តក្រុងស្រុកខណ្ឌ បានកំណត់អំពីគោលការណ៍ និងដំណើការ ផ្ទេមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានលទ្ធភាពសមសម្របក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។

### ប្រភេទនៃមុខងារ

- មុខងារដែលត្រូវផ្ទេរដោយក្រសួងស្ថាប័នរបស់រដ្ឋាភិបាលឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិមានពីរប្រភេទគឺះ
  - **មុខងារជាកាតព្វកិច្ច** គឺជាមុខងារ ដែលមានលក្ខណៈជាតម្រូវការចាំបាច់ ហើយដែលត្រូវបានកំណត់ ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ជាសមត្ថកិច្ចរបស់អង្គភាព ឬស្ថាប័នជាក់លាក់ណាមួយ។ មុខងារជាកាតព្វកិច្ច ត្រូវភ្ជាប់ជាមួយនូវថវិកា ធនធាន មនុស្ស និងសមត្ថភាពសមស្របដែលចាំបាច់ ដើម្បីអនុវត្តមុខងារនោះ។
  - **មុខងារជាជម្រើស** គឺជាមុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច ហើយដែលត្រូវបានកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស។ ការផ្ទេរមុខងារជាជម្រើសដោយក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលឲ្យទៅប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្រប ត្រូវធ្វើឡើងដោយប្រគល់។

### ក.គោលការណ៍នៃការផ្ទេរមុខងារ

ជាគោលការណ៍ ការផ្ទេរមុខងារត្រូវធ្វើឡើងដោយផ្សារភ្ជាប់ជាមួយនឹងការផ្ទេរធនធានចាំបាច់ និងត្រូវធ្វើឡើងដោយមានការគ្រោងទុក មានសនិទានភាព មានការសម្របសម្រួល ការពិគ្រោះយោបល់ មានតម្លាភាព និងមានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការ។ មាត្រា២១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីវិស័យជាអាទិភាពសម្រាប់ការពិនិត្យមើលឡើងវិញដោយក្រសួងស្ថាប័នថ្នាក់ជាតិ ដើម្បីកំណត់ថាមុខងារណាដែលត្រូវផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារណាដែលត្រូវរក្សាទុកជាការទទួលខុសត្រូវរបស់ថ្នាក់ជាតិ។

### វិស័យអាទិភាពទាំងនោះរួមមានះ

- កសិកម្ម
- អប់រំ
- ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី
- បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដីធ្លី
- ការផលិត និងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារៈចាំបាច់ ដើម្បីគាំទ្រ និងថាត់ចែងការ ទទួលខុសត្រូវទាំងនេះ
- និងតម្រូវការពិសេស ឬតម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ។

- ទន្ទឹមនេះ ក្នុងការពិនិត្យមើលមុខងារដើម្បីផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័ន ត្រូវផ្តល់អាទិភាព ទៅលើមុខងារជាមូលដ្ឋាន និងចាំបាច់ ដែលមានផលប៉ះពាល់ផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អ គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយត្រូវផ្អែកលើ គោលការណ៍ ដូចខាងក្រោម៖
  - ទី១៖ ការផ្ទេរមុខងារត្រូវផ្អែកទៅលើគោលការណ៍នៃ Subsidiarity។ មុខងារណាដែល ពិនិត្យឃើញថា មានលក្ខណៈនៅកៀកប្រជាពលរដ្ឋ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តបាន ប្រកបដោយប្រសិទ្ធភាព ក្រសួង ស្ថាប័នថ្នាក់ជាតិត្រូវពិនិត្យផ្ទេរមុខងារទាំងនោះទៅឲ្យរដ្ឋបាលថ្នាក់ ក្រោមជាតិ។ ក្នុងការផ្ទេរមុខងារ ទាំងនេះ ក្រសួង ស្ថាប័នថ្នាក់ជាតិគួររក្សាទុកតែផ្នែកណាដែលមាន លក្ខណៈជាការរៀបចំគោលនយោបាយ ជាការកំណត់ស្តង់ដារអប្បបរមារបស់ជាតិ និង/ឬជាការគាំទ្រ ការតាមដាន ការវាយតម្លៃ និងការត្រួតពិនិត្យ ជាដើម។
  - ទី២៖ ដើម្បីធ្វើការផ្ទេរមុខងារឲ្យបានសមស្របសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវពិនិត្យមើលមុខងារទាំងនោះទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ដើម្បីធ្វើការ សម្រេចថា តើមុខងារ សមស្របណាខ្លះដែលគួរត្រូវផ្ទេរទៅឲ្យថ្នាក់រដ្ឋបាលសមស្របណាមួយនៅ ថ្នាក់ក្រោមជាតិ។ លក្ខណៈវិនិច្ឆ័យ សម្រាប់ពិចារណាក្នុងការផ្ទេរមុខងារ រួមមាន៖
    - ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
    - អាចគ្រប់គ្រង និងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
    - បម្រើឬផ្តល់ផលប្រយោជន៍ជាចម្បង ដល់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
    - មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ។
  - ទី៣៖ ក្នុងការផ្ទេរមុខងារ ក្រសួង ស្ថាប័នថ្នាក់ជាតិដែលផ្ទេរមុខងារនោះត្រូវកំណត់ថា មុខងារនោះជាមុខងារ ជាកាតព្វកិច្ច ឬមុខងារជាជម្រើស។
  - ទី៤៖ ការផ្ទេរមុខងារ និង/ឬ ធនធាន ឲ្យទៅប្រភេទក្រុមប្រឹក្សាណាមួយដែលសមស្របតាមការប្រគល់ ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងតាមគោលការណ៍នៃការប្រគល់ ឬការធ្វើប្រតិភូកម្មជាលក្ខណៈអចិន្ត្រៃយ៍ ដោយមិនត្រូវធ្វើការប្រគល់ ឬប្រតិភូកម្មជាលក្ខណៈបណ្តោះអាសន្នឡើយ។ ក្នុងការផ្ទេរមុខងារជាកាតព្វកិច្ច ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវកំណត់ឲ្យបានច្បាស់លាស់ អំពីតម្រូវការធនធានចាំបាច់ដែលត្រូវផ្ទេរក៏ដូចក្របខ័ណ្ឌ ពេលវេលាសម្រាប់អនុវត្តបទដ្ឋាន និង នីតិវិធី។
  - ទី៥៖ ការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស។

### ខ.ដំណើការផ្ទេមុខងារ

ដើម្បីជំរុញដំណើរការផ្ទេរមុខងារពីក្រសួងស្ថាប័នទៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ អនុក្រឹត្យលេខ ៦៨ អនក្របក ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យ ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងផ្តល់ការណែនាំទូទៅដល់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អំពីដំណើរការ ផ្ទេរមុខងារ។ ក្រសួងស្ថាប័នដែលស្ថិតក្នុងវិស័យអាទិភាពត្រូវរៀបចំបញ្ជីវិភាគមុខងារនៅក្នុងក្រសួង ស្ថាប័នរបស់ខ្លួនហើយ បន្ទាប់មកត្រូវពិនិត្យមើលមុខងារ ទាំងនោះឡើងវិញ ដើម្បីកំណត់អំពីមុខងារ និងធនធានសមស្របដែលត្រូវផ្ទេរទៅឲ្យទៅ រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងដំណើរការផ្ទេរមុខងារ គ.ជ.អ.ប ដែលជាយន្តការអន្តរក្រសួង និងដែលមានលេខាធិការដ្ឋាន គ.ជ.អ.ប ជាសេនាធិការ គឺជាអ្នកសម្របសម្រួលនៅក្នុងកិច្ចការនេះ។

- ពាក់ព័ន្ធការងារនេះ ក្រសួងក្នុងវិស័យអាទិភាពចំនួន ១៤ បានធ្វើការវិភាគមុខងារ និងពិនិត្យមុខងារឡើងវិញដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន៖
  - ក្រសួងអប់រំ យុវជន និងកីឡា
  - ក្រសួងអភិវឌ្ឍជនបទ
  - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  - ក្រសួងបរិស្ថាន
  - ក្រសួងសុខាភិបាល
  - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  - ក្រសួងទេសចរណ៍
  - ក្រសួងពាណិជ្ជកម្ម
  - ក្រសួងរ៉ែ និងថាមពល
  - ក្រសួងសាធារណការ និងដឹកជញ្ជូន
  - ក្រសួងធនធានទឹក និងឧតុនិយម
  - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
  - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
  - មកទល់បច្ចុប្បន្ននេះ ក្រសួងចំនួន១០បានដាក់ចេញរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងបញ្ជីពិនិត្យមុខងារឡើងវិញរួមមាន៖
    - ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងអភិវឌ្ឍជនបទ
    - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
    - ក្រសួងបរិស្ថាន
    - ក្រសួងសុខាភិបាល
    - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
    - ក្រសួងទេសចរណ៍
    - ក្រសួងសាធារណការ និងដឹកជញ្ជូន
    - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
    - ក្រសួងរ៉ែ និងថាមពល។
  - មុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
    - អាណត្តិទូទៅ ជាប្រភេទនៃមុខងារជាជម្រើសដែលត្រូវបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធហើយរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើសអនុវត្តមុខងារទាំងនោះ ដើម្បីឆ្លើយតបតម្រូវការចាំបាច់របស់មូលដ្ឋានខ្លួន ប្រសិនមិនមានការជំទាស់ពីក្រសួង ស្ថាប័ន នានា និងមិនមានការហាមឃាត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ មុខងារនេះ ត្រូវបានប្រគល់ទៅឲ្យក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ មុនការធ្វើប្រតិភូកម្ម ឬ ការប្រគល់មុខងារជាក់លាក់ណាមួយដើម្បីជាមូលដ្ឋានក្នុងការលើកកម្ពស់សមត្ថភាពដល់រដ្ឋ បាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារ

ផ្សេងៗគ្នាជាច្រើន ដែលបានជ្រើសរើសយកជាអាទិ ភាពតាមមូលដ្ឋាននីមួយៗ។ បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងបំពេញការងារប្រចាំថ្ងៃ ដោយផ្អែកលើផ្នែកលើមុខងារជាអាណត្តិទូទៅ។

- វិសាលភាពនៃការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានកំណត់ដោយច្បាប់ អនុក្រឹត្យ និង/ឬ ប្រកាស ជាអាទិ៍មានដូចជា៖
  - ច្បាប់រៀបចំអង្គការ
  - អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
  - អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈ អភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
  - អនុក្រឹត្យស្ដីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  - ប្រកាសស្ដីពីការបង្កើតការិយាល័យ ចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបប ការងារនៃការិយាល័យទាំងនោះ
  - ប្រកាសស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់ តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះជាដើម។ល។

- ផ្អែកតាមមុខងារជាអាណត្តិទូទៅ និងផ្អែកតាមធនធានដែលមាន រដ្ឋបាលថ្នាក់ក្រោមជាតិ មួយៗមានស្វ័យភាពបំពេញមុខងារក្នុងការ៖
  - រៀបចំ និងពង្រឹងការអនុវត្តបទប្បញ្ញត្តិមូលដ្ឋាននានាពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ច
  - លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងភាពជាដៃគូ ជាមួយអង្គការសហគមន៍ និងវិស័យឯកជន
  - ធានាដល់ការផ្តល់សេវាសុវត្ថិភាពសង្គមសម្រាប់ប្រជាពលរដ្ឋទីទ័លក្រ និងក្រុមជនងាយរងគ្រោះ
  - ផ្តល់ហិរញ្ញប្បទានរួមគ្នាឬបង្កើតរួមគ្នានូវសេវានានាដែលគ្រប់គ្រងដោយថ្នាក់ជាតិ
  - អភិវឌ្ឍនិងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនានាដែលពុំត្រូវបានកំណត់ថា ជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នផ្សេងទៀត
  - អនុវត្តកិច្ចការផ្សេងទៀត ដើម្បីផលប្រយោជន៍ផ្នែកសុខុមាលភាពរបស់សហគមន៍ដែលច្បាប់មិនបានហាមឃាត់។

### គ.មុខងារជាភ្នាក់ងារ

ក្រៅពីមុខងារខាងលើ រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីអនុវត្តមុខងារជាភ្នាក់ងាររបស់រាជរដ្ឋាភិបាលនិងក្រសួងស្ថាប័នថ្នាក់ជាតិ។ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ គឺជាអ្នកដែលទទួលបានការធ្វើប្រតិភូកម្មពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងនោះមានដូចជា៖

- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ឈប់ភារកិច្ចរបស់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ការចុះបញ្ជីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់
- ការចុះឈ្មោះបោះឆ្នោតនិងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ជាដើម។

- ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យភាពនៅក្នុងការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការមួយចំនួនដែលក្នុងនោះមានដូចជាការរៀបចំឲ្យមានបញ្ជីសេវារដ្ឋបាល និងនីតិវិធីទទួលសេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុក្រឹត្យស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងក្នុងគោលបំណងធានានូវការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន ប្រមាណជាង២០០សេវា។
- ដោយឡែក ពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក អនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ បានធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានី ខេត្ត ក្នុងការចេញដីកាតែងតាំង ផ្លាស់ប្តូរនិងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលចាប់ពីៈ
  - ថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត
  - ថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌ
  - ថ្នាក់ក្រោមប្រធានមន្ទីរជំនាញ
  - ថ្នាក់ប្រធានការិយាល័យជំនាញចុះ។
- ចំពោះការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចប្រធានមន្ទីរជំនាញ អភិបាលរាជធានីខេត្តបានទទួលប្រតិភូកម្មអំណាចក្នុងការ "លើកសំណើ" ទៅក្រសួងស្ថាប័ននៅថ្នាក់ជាតិ។
- ម្យ៉ាងទៀត ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការតាមដានត្រួតពិនិត្យការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់នូវសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរួមចំណែកដល់ការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឲ្យកាន់តែមានប្រសិទ្ធភាព។

## ៦.ថវិកាថ្នាក់ក្រោមជាតិ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឲ្យរដ្ឋបាល ថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុសមស្រប ដើម្បីបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងត្រូវ គ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព មានតម្លាភាព និងមានគណនេយ្យភាព។ មាត្រា២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីប្រភេទចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺ

- ចំណូលពីប្រភពនៅមូលដ្ឋាន រួមមានៈ
  - ពន្ធនៅមូលដ្ឋាន
  - ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត
  - ចំណូលរបស់ក្រុមប្រឹក្សាស្រុក បានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែក
  - អំណោយស្ម័គ្រចិត្តរវាងក្រុមប្រឹក្សាស្រុក ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
  - ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យ។

- ចំណូលពីថ្នាក់ជាតិ រួមមានៈ
    - ចំណូលចែករំលែក
    - មូលនិធិផ្ទេរពីថវិការដ្ឋ
    - ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័ន។
- ផ្អែកលើបទប្បញ្ញត្តិនៃច្បាប់រៀបចំអង្គការ បានតម្រូវឲ្យរៀបចំច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។
- ដើម្បីធានារៀបចំឲ្យប្រព័ន្ធផ្ទេរថវិកាពីថវិកាជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយ តម្លាភាព គណនេយ្យភាព និងមានសមធម៌ រាជរដ្ឋាភិបាលបានចាប់ផ្តើមបង្កើតមូលនិធិឃុំ សង្កាត់ បន្ទាប់មកគឺមូលនិធិក្រុង ស្រុក និងបានធ្វើការកែសម្រួលខ្លះៗនូវការរៀបចំថវិការាជធានី ខេត្ត។
- ដើម្បីធានាឲ្យមានតម្លាភាព គណនេយ្យភាព និងសមធម៌ក្នុងការទទួលបានធនធានពី ថ្នាក់ជាតិ ការផ្ទេរមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ទៅឲ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាល ឃុំ សង្កាត់នីមួយៗ ត្រូវធ្វើឡើងតាមរូបមន្តកំណត់ជាក់លាក់មួយដូចខាងក្រោមៈ
    - សម្រាប់ឃុំ សង្កាត់ៈ ចំណែកស្មើគ្នា ចំនួនប្រជាពលរដ្ឋ និងសន្ទស្សន៍ភាពក្រីក្រ
    - សម្រាប់ក្រុង ស្រុកៈ ចំណែកស្មើគ្នា ចំនួនប្រជាពលរដ្ឋ សន្ទស្សន៍ភាពក្រីក្រ និងចំនួនឃុំ សង្កាត់។